# សុន្ទរកថា

## ស្វាគមន៍ និង របាយការណ៍

## ថ្លែងដោយ បណ្ឌិត កៅ គឹមហួន ប្រធានសាកលវិទ្យាល័យកម្ពុជា

## ស្តីពី

## ការប្រឡងជ្រើសរើសសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេសអោយទទួល

## « អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨ »

សាកលវិទ្យាល័យកម្ពុជា

ព្រឹកថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៨ វិទ្យាស្ថាន ជាតិអប់រំ

ឆ្នាំសិក្សា ២០០៨ - ២០១២

**សូមគោរពៈ**

- **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

- **សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ ជាទីគោរព** !

ថ្ងៃនេះ សាកលវិទ្យាល័យកម្ពុជា មានសេចក្តីសោមនស្សរីករាយ និងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានរៀបចំពិធីប្រគល់ « **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** » ជូនសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស ចំនួន ៥០០ កន្លែង ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់របស់ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ ។

ក្នុងនាម សាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទសូមសម្តែងនូវសេចក្តីដឹងគុណ និង សូមស្វាគមន៍ ដោយស្មោះ ចំពោះវត្តមាន ដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី និង លោកជំទាវ** ក្នុងពិធីប្រគល់ **អាហារូបករណ៍ជាតិ** ដ៏មានសារៈសំខាន់នេះ ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ ដែលបានផ្តល់កិត្តិយស អញ្ជើញចូលរួមក្នុងពិធីជាប្រវត្តិសាស្ត្រនេះ ។

**សម្តេចតេជោ នាយករដ្ឋមន្ត្រី និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**
**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីគោរព !**

**អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** គឺជាអាហារូបករណ៍ ថ្នាក់បរិញ្ញាប័ត្រទ្រង់ទ្រាយធំមួយ នៅសាកលវិទ្យាល័យកម្ពុជា សំរាប់ឆ្នាំសិក្សា ២០០៨ – ២០១២ ។ អាហារូបករណ៍នេះមាន **ចំនួន ៥០០ កន្លែង** ។ គឺជា អាហារូបករណ៍ពេញថ្លៃ ១០០% ។ សិស្សានុសិស្សថ្នាក់មធ្យមសិក្សាទូទាំងប្រទេស ដែលអាចដាក់ពាក្យស្នើសុំចូលប្រកួតប្រជែងយក អាហារូបករណ៍នេះបាន គឺជាសិស្សានុសិស្សថ្នាក់ទី ១២ ដែលបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំ ២០០៧ - ២០០៨ និង បានទទួលនិទ្ទេស A – B – C ឬ D ក្នុងការប្រឡង នោះ ។

សាកលវិទ្យាល័យកម្ពុជា សូមសម្តែងនូវសេចក្តីដឹងគុណ ដ៏ខ្ពង់ខ្ពស់ចំពោះ **សម្តេចនាយករដ្ឋមន្ត្រី** និង **លោកជំទាវ** ដែលបានអនុញ្ញាតឱ្យ សាកលវិទ្យាល័យកម្ពុជា ប្រសិទ្ធិនាមអាហារូបករណ៍នេះ ថា « **អាហារូបករណ៍ ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** » តាមចំណារអនុញ្ញាត **ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨** ។ នេះគឺជា មហាករុណាទិគុណរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលយើងខ្ញុំពុំអាចបំភ្លេចបាន ។ **អាហារូបករណ៍ ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** ឧបត្ថម្ភដោយ **បណ្ឌិត** Haruhisa Handa ស្ថាបនិក និងជាប្រធានមូលនិធិអន្តរជាតិ ដើម្បីសិល្បៈ និង វប្បធម៌ នៃប្រទេសជប៉ុន និងជា អធិការបតី នៃសាកលវិទ្យាល័យកម្ពុជា ។ សាកលវិទ្យាល័យកម្ពុជា ក៏ដូចជាមាតាបិតា និង អាណាព្យាបាល របស់សិស្សានុសិស្ស

ដែលបានទទួលអាហារូបករណ៍នេះ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ បំផុតចំពោះ **លោកបណ្ឌិត** Haruhisa Handa និង អង្គការ របស់លោកដែលបានឧបត្ថម្ភអាហារូបករណ៍ ដ៏សប្បុរសនេះ ។

**សម្តេចនាយករដ្ឋមន្ត្រី និង លោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ !**

គោលដៅជាសក្តានុពល នៃការបង្កើតឱ្យមាន « **អាហារូបករណ៍ ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** » បន្តពីឆ្នាំ ២០០៧ គឺដើម្បី ៖

១. ចូលរួមអភិវឌ្ឍធនធនមនុស្ស ពិសេសគឺ ធនធនបញ្ញវន្តវ័យក្មេងបន្តវេន ដែលនឹងក្លាយទៅជាកម្លាំងគ្រឹះ និង ជាសសរទ្រូងរបស់ប្រទេសជាតិយើងទៅអនាគត ;

២. លើកស្ទួយការអប់រំថ្នាក់ឧត្តម និង ការអភិវឌ្ឍសមត្ថភាព និង ធនធានខាងបញ្ញា ដើម្បីប្រទេសជាតិយើង ឆ្លើយតបបានយ៉ាងល្អប្រសើរទៅនឹង ចរន្តនៃសាកលភាវូបនីយកម្ម ក៏ដូចជាដើម្បីជួយជម្រុញ ឱ្យប្រទេសកម្ពុជាអាចធ្វើសមាហរណកម្មបានយ៉ាងពេញលេញ ទៅ ក្នុងតំបន់ និង លើពិភពលោក ;

៣. ផ្តល់ឱកាស និង ការសិក្សាជូននិស្សិតក្រីក្រដែលមកពីជនបទ កាន់តែច្រើនថែមទៀត ដើម្បីអោយគេបានបន្តការសិក្សាទៅថ្នាក់ឧត្តម ;

៤. រួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងនូវកាលានុវត្តភាពអប់រំ ការបង្កើនឱកាសដើម្បីស្វែងរកការងារជូននិស្សិតក្នុងពេលដែលគេកំពុងសិក្សា និង ក្រោយពេលដែលគេបញ្ចប់ការសិក្សារបស់គេ ;

៥. ចូលរួមស្ថាបនា និង អភិវឌ្ឍសង្គមបញ្ញវន្តខ្មែរមួយ ដើម្បីជួយអភិវឌ្ឍប្រទេសកម្ពុជាអោយរុងរឿងទៅអនាគត ។

ដើម្បីសំរេចគោលដៅនេះ សាកលវិទ្យាល័យកម្ពុជា បានធ្វើការផ្សព្វផ្សាយ និង ជ្រើសរើសអ្នកទទួលអាហារូបករណ៍នេះ ក្នុងចំណោមបេក្ខជន ជាសិស្សានុសិស្សដែលអញ្ជើញមកពី សាលាមធ្យមសិក្សា **ខេត្ត - ក្រុង**

ចំនួន ៥៣១០ នាក់ ក្នុងនោះមាន បេក្ខជនចំនួន ២៨៧២ នាក់ និង បេក្ខនារីចំនួន ២៤៣៨ នាក់ តាមរយៈការប្រឡងប្រជែង ប្រកបដោយតម្លាភាព និង យុត្តិធម៌ នៅសាកលវិទ្យាល័យកម្ពុជា នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ។ សិស្សានុសិស្សដែលមានកំរិតយល់ដឹង និង សមត្ថភាពអាចទទួលយក **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ - ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** សាកលវិទ្យាល័យកម្ពុជា ឆ្នាំ ២០០៨ - ២០១២ មានចំនួន ៥០០ នាក់ ដែលក្នុងនោះ សិស្សានុសិស្សជាបេក្ខជន មានចំនួន ២៩០ នាក់ និង បេក្ខនារី មានចំនួន ២១០ នាក់ ។

- **សម្តេចនាយករដ្ឋមន្ត្រី និង លោកជំទាវ**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**
- **ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីគោរព !**

និស្សិត **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ - ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** ពី **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង **លោកជំទាវ** ដោយផ្ទាល់នៅព្រឹកនេះ នឹងចាប់ផ្តើមចូលសិក្សានៅ សាកលវិទ្យាល័យកម្ពុជា ដើម្បីយកសញ្ញាប័ត្រ ថ្នាក់បរិញ្ញា លើមុខវិជ្ជាសំខាន់៧មួយចំនួន ចាប់តាំងពី ឆមាសទី ១ ឆ្នាំ ២០០៨ នេះរហូតដល់ឆ្នាំ ២០១២ ។

សង្ឃឹមថា ដល់ឆ្នាំ ២០១២ និស្សិតទាំងអស់នឹងបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាប័ត្ររបស់ខ្លួន ប្រកបដោយជោគជ័យ នឹងបានក្លាយជា បញ្ញវន្តស្ថាបនិកសង្គមថ្មីដ៏ខ្លាំងក្លា និង បន្តការសិក្សាទៅថ្នាក់ឧត្តមទៀត ប្រកបដោយមោទនភាព ។

ជាថ្មីម្តងទៀត នៅទីបញ្ចប់នេះ ក្នុងនាមសាកលវិទ្យាល័យកម្ពុជា ខ្ញុំបាទសូមសម្តែងនូវ សេចក្តីដឹងគុណដ៏ខ្ពង់ខ្ពស់ចំពោះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង **លោកជំទាវ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមជា ប្រធានគណៈអធិបតី ដ៏ខ្ពង់ខ្ពស់ក្នុងពិធី ប្រគល់ប័ណ្ណអាហារូបករណ៍នេះ ។

សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមជា កិត្តិយសក្នុងពិធីនេះ ; និង

សូមគោរពជូនពរ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង **លោកជំទាវ** ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តយសជាតិ និង អន្តរជាតិ សូមអោយបានប្រកបដោយ ជោគជ័យ សិរីមង្គល និង វិបុលសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**